# ធនាគារពិភពលោកឆ្លើយបំភ្លឺចំពោះអត្ថបទដែលផ្សាយក្នុងការសែតស្តីអំពីគំរោងនៅកម្ពុជា

៣ ឆ្នាំ មកហើយ ដែលធនាគារពិភពលោក បានប្តូរការយកចិត្តទុកដាក់ចំពោះការចូលរួមរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា ទៅលើការប្រយុទ្ធប្រឆាំងអំពើពុករលួយ និងការខិតខំប្រឹងប្រែងដើម្បីកែលំអអភិបាលកិច្ច ដែលវាជាការងារស្នូលរបស់ខ្លួន ។ ការងារស្នូលទាំងនេះមានន័យទូលំទូលាយ លើការខិតខំប្រឹងប្រែងជាសលកដើម្បីរឹងបន្តឹងការប្រយុទ្ធប្រឆាំងទៅនឹងអំពើពុករលួយ ហើយទទួលស្គាល់ថា វាជាឧបសគ្គដ៏ធំចំពោះការលូតលាស់ និងការកាត់បន្ថយភាពក្រីក្រ ។

គំរោងដែលគាំទ្រដោយធនាគារពិភពលោក នាពេលបច្ចុប្បន្ន កំពុងបង្ហាញការបញ្ជាក់ដ៏ច្បាស់លាស់មួយ លើការចូលរួមដោយផ្ទាល់ នៅក្នុងវិស័យដែលអំពើពុករលួយបង្កជាបញ្ហា និងនៅក្នុងការកែទំរង់ដែលមានសារៈសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ និងការទាក់ទាញការវិនិយោគ។ ធនាគារពិភពលោកបានពង្រឹងការងាររបស់ខ្លួនលើគំរោង និងការស្រាវជ្រាវដែលធ្វើអោយមានការកែលំអប្រព័ន្ធហិរញ្ញវត្ថុ និងលាតត្រដាងអំពើពុករលួយ។

ធនាគារពិភពលោកក៏បានគាំទ្ររដ្ឋាភិបាលលើកម្មវិធីកំណែទំរង់មួយចំនួន ដែលរៀបចំឡើងដើម្បីកែលំអអភិបាលកិច្ច និងការគ្រប់គ្រងសេដ្ឋកិច្ច កាត់បន្ថយតំលៃការធ្វើជំនួញនានា និងការកែលំអការអភិវឌ្ឍវិស័យឯកជន ការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគណនេយ្យភាព និងការគាំទ្រវិមជ្ឈការ ។

មួយផ្នែកនៃគោលគំនិតនេះ ធនាគារពិភពលោក និងរដ្ឋាភិបាល បានរៀបចំអោយមានការពិនិត្យឡើងវិញទៅលើការប្រើប្រាស់ថវិកា (Fiduciary Review) ហើយបន្ទាប់មករដ្ឋាភិបាលបង្កើតកម្មវិធី (១) ដើម្បីកាត់បន្ថយឱកាសសំរាប់ប្រព្រឹត្តិអំពើពុករលួយ តាមរយៈការរឹតបន្តឹងច្បាប់ និងការត្រួតពិនិត្យ និងបង្កអោយមានប្រកួតប្រជែងដ៏ទូលំទូលាយ និងការធ្វើអោយប្រសើរចំពោះតម្លា និងការផ្សព្វផ្សាយឯកសារនានា ហើយ (២) ទប់ស្កាត់ការធ្វើខុសតាមរយៈការអនុវត្តការដាក់ទណ្ឌកម្មដ៏តឹងរឹង។ ធនាគារពិភពលោកចាប់ផ្តើមក្នុងការស៊ើបអង្កេតគំរោងមួយចំនួន ហើយអនុវត្តការងារនេះ ទៅតាមការស្នើរឡើងរបស់សាធារណៈជនដែលស្នើសុំអោយមានការស៊ើបអង្កេត នៅក្នុងគំរោងទាំងនោះ ។

គំរោងទាំងអស់មាន ៧ គំរោងដែលធ្វើការស៊ើបអង្កេតដោយនាយកដ្ឋានសុក្រិតភាពរបស់ធនាគារពិភពលោក (គំរោង ៤ កំពុងអនុវត្ត និង គំរោង ៣ បានបញ្ចប់) ហើយបញ្ហាត្រូវបានរកឃើញកើតមានឡើងនៅក្នុងកិច្ចសន្យាជាក់លាក់មួយចំនួននៅក្នុងគំរោងនីមួយៗ។ បញ្ហាទាំងនោះមានដូចជាការប្រើប្រាស់ថវិការមិនត្រឹមត្រូវ និងកំហុសឆ្គងលើផ្នែកលទ្ធកម្ម (មានន័យថាវិធានសំរាប់ចំណាយសំរាប់ទំនិញ និងសេវាកម្មមិនបានគោរព) ។ រដ្ឋាភិបាលបានអនុវត្តសកម្មភាពជាបន្ទាន់ និងផ្អាក់ការបញ្ចេញលុយលើគំរោងបីដែលកំពុងដំណើរការ ដើម្បីកាត់បន្ថយកំរិតនៃការខូចខាត។

មានជំរើសមួយចំនួនដែលអាចធ្វើឡើងបានសំរាប់រដ្ឋាភិបាល និងធនាគារពិភពលោក ដើម្បីឆ្លើយតបទៅនឹងការរកឃើញនៅក្នុងការស៊ើបអង្កេតនេះ ។ ជាឧទាហរណ៍ ជំរើសទាំងនោះរួមមាន ការស្វែងរកការបង់សងត្រលប់វិញចំពោះប្រាក់ប្រើប្រាស់មិនត្រឹមត្រូវ និងការផ្អាក់ ឬបិទគំរោងដែលមានបញ្ហា ។

រដ្ឋាភិបាល និងធនាគារពិភពលោក កំពុងតែពិភាក្សាអំពីជំរើសទាំងនោះ ក៏ដូចជាពិភាក្សាលើមធ្យោបាយដើម្បីពង្រឹងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ការកែលំអសវនកម្ម និងតម្លាភាព ដើម្បីកាត់បន្ថយឱកាសផ្សេងៗក្នុងការប្រព្រឹត្តអំពើពុករលួយ ទាំងនៅក្នុងគំរោងដែលគាំទ្រដោយធនាគារពិភពលោក ហើយជាពិសេសជាងនេះទៅទៀត នៅក្នុងវិស័យនានានៃសេដ្ឋកិច្ច និងសង្គមរបស់កម្ពុជា។ បញ្ហានេះគឺមានសារសំខាន់ណាស់ដើម្បីអោយមានភាពប្រាកដប្រជាថាគោលដៅនៃការកាត់បន្ថយភាពក្រីក្រនៅប្រទេសកម្ពុជាត្រូវបានទទួល ហើយធានាថាប្រជាជនកម្ពុជាអាចទទួលបានជីវភាពប្រសើរនាពេលនាគត ។

ធនាគារពិភពលោក មានការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយនៅកម្ពុជា ។ យើងក៏បន្តធ្វើការជាមួយរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានា ដើម្បីដោះស្រាយបញ្ហាអភិវឌ្ឍន៍ដ៏ធំធេងនេះ ធ្វើការស៊ើបអង្កេតនៅទីណាដែលអាចកើតមានផ្អាក់ ឬលុបចោលគំរោងដែលកើតមានបញ្ហាប្រសិនបើចាំបាច់ ពង្រឹងការខិតខំដើម្បីកែលំអអភិបាលកិច្ច និងកាត់បន្ថយឱកាសសំរាប់ ប្រព្រឹត្តិអំពើពុករលួយ ហើយនឹងព្យាយាមយ៉ាងអស់ពីចិត្តដើម្បីធ្វើយ៉ាងណាធានាថា ជំនួយ និងធនធាននានា ត្រូវបានគេប្រើ ប្រាស់ដើម្បីកែលំអជីវភាពរស់នៅរបស់ប្រជាជនក្រីក្រ ។

ប្រសិនបើមានសំណួរសូមសួរទៅលោកស្រី គីមប៊ើលី វើសាក់ មន្ត្រីទំនាក់ទំនងព័ត៌មានធនាគារពិភពលោក ប្រចាំទីក្រុងបាងកក
អ៊ីមែល kversak@worldbank.org